01322202

E378/3

**ឯកសារដើម**
**ORIGINAL DOCUMENT/DOCUMENT ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 26 / 08 / 2016
ម៉ោង (Time/Heure) : 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

**សាធារណៈ / Public**

ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ប្រធានគណៈមេធាវីនីក្រុងអាំស្ទ័រដាំ

**ពី៖** ចៅក្រម យ៉ា សុខន ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ភាគីទាំងអស់នៃសំណុំរឿង ០០២

**កម្មវត្ថុ៖** សំណើសុំព័ត៌មានបន្ថែមពាក់ព័ន្ធនឹងកំហុសវិជ្ជាជីវៈដែលអាចមានរបស់មេធាវី ១ រូបដែលបានចុះបញ្ជីនៅគណៈមេធាវីរបស់លោក/លោកស្រី - លោក Victor KOPPE

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានទទួលលិខិតពីលោក/លោកស្រី ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៦ ដែលបានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា លោក Victor KOPPE បានឆ្លើយតបទៅនឹងលិខិតរបស់លោក/លោកស្រីចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ហើយ ដែលនៅក្នុងលិខិតនោះ លោក/លោកស្រីបានលើកឡើងពីបណ្តឹងរបស់ អ.វ.ត.ក ចំពោះការការប្រព្រឹត្តិរបស់គាត់នៅក្នុងតុលាការ (ឯកសារ E378)។

អង្គជំនុំជម្រះកត់សម្គាល់ថា ជំហានបន្ទាប់នៅក្នុងដំណើរការនីតិវិធីគឺការឆ្លើយតបជាលាយលក្ខណ៍អក្សររបស់អង្គជំនុំជម្រះចំពោះអំណះអំណាងការពារខ្លួនរបស់លោក Victor KOPPE។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានទទួលចម្លើយតបរបស់លោក Victor KOPPE ទៅនឹងបណ្តឹងប្រឆាំងនឹងរូបលោកនៅឡើយទេ។ ទោះបីជាលិខិតឆ្លើយឆ្លងរបស់លោក/លោកស្រី ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៦ បានយោងទៅ "លិខិតរបស់លោក Victor KOPPE ចុះថ្ងៃទី ២១ ខែ

មេសា ឆ្នាំ ២០១៦ និង ឧបសម្ព័ន្ធនានានៃលិខិត” នោះក៏ដោយ ក៏ប៉ុន្តែឯកសារទាំងនេះមិនមានភ្ជាប់មកជាមួយនៅក្នុងលិខិតឆ្លើយឆ្លងទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងស្នើសុំលោក/លោកស្រី ជួយបញ្ជូនលិខិតរបស់លោក Victor KOPPE និង ឧបសម្ព័ន្ធនានានៃលិខិតនោះ មកអង្គជំនុំជម្រះឱ្យបានឆាប់តាមដែលអាចធ្វើបាន។

បន្ថែមពីលើនេះ អង្គជំនុំជម្រះកត់សម្គាល់ថា លិខិតឆ្លើយឆ្លងរបស់លោក/លោកស្រី ពុំមានលើកឡើងពីសេចក្តីបន្ថែមរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឡើយ (ឯកសារ E378/1)។ តាមរយៈការលើកឡើងនៅក្នុងសេចក្តីបន្ថែម អង្គជំនុំជម្រះបានជូនដំណឹងអំពីការប្រព្រឹត្តិបន្ថែមរបស់លោក Victor KOPPE ចាប់ពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ដែលអង្គជំនុំជម្រះយល់ឃើញថាការប្រព្រឹត្តិនេះអាចជាកំហុសកំហុសវិជ្ជាជីវៈនៅចំពោះមុខ អ.វ.ត.ក ដូចដែលមានចែងក្នុងវិធាន ៣៨(១) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសូមស្នើសុំលោក/លោកស្រី ពិចារណាលើសេចក្តីបន្ថែមនៅក្នុងឯកសារ E378/1 រួមជាមួយការចោទប្រកាន់ដែលបានរៀបរាប់នៅក្នុងឯកសាររបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ (ឯកសារ E378)។

ហេតុនេះ អង្គជំនុំជម្រះស្នើសុំឱ្យលោក/លោកស្រី មេត្តាបញ្ជាក់ថា តើលោក/លោកស្រី បានទទួលសេចក្តីបន្ថែមចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដែរ ឬទេ (ឯកសារ E378/1) និងស្នើសុំបញ្ចូលវាទៅក្នុងការស៊ើបអង្កេតអំពីកំហុសវិជ្ជាជីវៈដែលអាចមានរបស់លោក Victor KOPPE។ សម្រាប់ជាឯកសារយោងដល់លោក/លោកស្រី អង្គជំនុំជម្រះក៏បានភ្ជាប់ឯកសារ E378/1 និង ឧបសម្ព័ន្ធនានានៃឯកសារជាមួយនឹងលិខិតនេះផងដែរ។

អង្គជំនុំជម្រះសូមស្នើលោក/លោកស្រីមេត្តាផ្តល់ឯកសារ និង ព័ត៌មានបន្ថែម ដែលបានស្នើសុំនៅក្នុងលិខិតនេះ មកអង្គជំនុំជម្រះឱ្យបានឆាប់ តាមរយៈមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ។

ប្រសិនបើលោក/លោកស្រីមានចម្ងល់ ឬ ត្រូវការព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

Ken Roberts (roberts13@un.org)
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
PO Box 71 រាជធានីភ្នំពេញ
ប្រទេសកម្ពុជា